ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE

東埔寨大众伦平保险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក ក្នុងប្រទេសកម្ពុជា

## កិច្ចសន្យាធានារ៉ាប់រងលើរថយន្តដឹកទំនិញ ឬអ្នកដំណើរ

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ :

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុងប៉ាក តីអិលស៊ី** |
| | | ជាន់ទី៧ នៃអគារកម្ពុបែង |
| | | ផ្ទះលេខ ២៣ ផ្លូវ ១១៤ |
| | | សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ |
| | | ១២០២០២ រាជធានីភ្នំពេញ |
| | | ព្រះរាជាណាចក្រកម្ពុជា |
| | | ប្រអប់សំបុត្រ ១៩៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីម៉ែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរស័ព្ទប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីម៉ែល : claims@campulonpac.com.kh

សំគាល់:

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។
យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់ និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាម ប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## កិច្ចសន្យាធានារ៉ាប់រងលើយានយន្តដឹកទំនិញ ឬអ្នកដំណើរ

## ប្រភេទនៃការធានារ៉ាប់រង

ផ្នែកដែលត្រូវយកមកអនុវត្តស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះមាន :

- ការធានារ៉ាប់រងគ្រប់ប្រភេទ : ផ្នែក **ក** និង **ខ** នៃកិច្ចសន្យាធានារ៉ាប់រងនេះត្រូវយកមកអនុវត្ត
- ការធានារ៉ាប់រងសម្រាប់តែតតិយជន : ផ្នែក **ខ** តែមួយប៉ុណ្ណោះដែលត្រូវយកមកអនុវត្ត

ត្រូវអនុវត្តផងដែរនូវបដិលេខ ខសន្យា ការធានាទាំងឡាយ ដែលមានភ្ជាប់នៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។

## ការព្រមព្រៀងរបស់ក្រុមហ៊ុន

ដោយហេតុថា លោកអ្នកបានដាក់ពាក្យស្នើសុំដើម្បីធានារ៉ាប់រងលើយានយន្តរបស់លោកអ្នកតាមរយៈទម្រង់បែបបទស្នើសុំការធានារ៉ាប់រង និងការអះអាងរបស់លោកអ្នក ដែលត្រូវក្លាយជាមូលដ្ឋាននៃកិច្ចសន្យានេះ និងដោយលោកអ្នកបានបង់នូវបុព្វលាភធានារ៉ាប់រងដែលបានកំណត់ នៅក្នុងតារាងឧបសម្ព័ន្ធស្របតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងដល់លោកអ្នកចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដូចមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ហើយដែលកើតឡើងនៅក្នុងអំឡុងពេលនៃការធានារ៉ាប់រងស្របតាមបញ្ញត្តិ លក្ខខណ្ឌ បដិលេខ ខសន្យានានា ឬការធានាអះអាងទាំងឡាយដែលជាផ្នែកនៃកិច្ចសន្យាធានារ៉ាប់រងនេះ។

## ផ្នែក ក ~ ការបាត់បង់ ឬការខូចខាតចំពោះយានយន្តរបស់លោកអ្នក

**១. ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងដល់លោកអ្នក ប្រសិនបើយានយន្តរបស់លោកអ្នកទទួលរងការខូចខាត ឬត្រូវបាត់បង់នៅក្នុងព្រឹត្តិការណ៍ទាំងឡាយដូចខាងក្រោម :**

(ក) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់យានយន្តដោយចៃដន្យ

(ខ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់យានយន្ត ដែលបណ្តាលមកពីការខូចគ្រឿងម៉ាស៊ីន

(គ) ដោយការប៉ះទង្គិចគ្នា ឬការក្រឡាប់យានយន្ត ដែលបណ្តាលមកពីភាពចាស់ សំណឹករេចរឹល

(ឃ) ដោយការខូចខាតដែលបណ្តាលពីការប៉ះទង្គិចដោយវត្ថុដែលធ្លាក់មកពីលើ ដែលការធ្លាក់នោះមិនបណ្តាលមកពីទឹកជំនន់ ខ្យល់ព្យុះសង្ឃរា ខ្យល់ព្យុះ ព្យុះភ្លៀង បន្ទុះភ្នំភ្លើង រញ្ជួយដី ការរអិលចុះនៃផ្ទាំងដី បំណាក់ស្រុតដី ការធ្លាក់ចុះ ឬលិចនៃផ្ទាំងដី (Subsidence or sinking of the soil/earth) ឬគ្រោះធម្មជាតិផ្សេងទៀត

(ង) ដោយសារបន្ទុះឆេះ ឬ រន្ទះ

(ច) ដោយការចូលលួច ការគាស់ផ្ទះ ឬអំពើចោរកម្ម ប៉ុន្តែការបាត់បង់គ្រឿងបន្ថែម ឬ ផ្នែកណាមួយនៃយានយន្តមិនត្រូវបានធានារ៉ាប់រងឡើយ លុះត្រាតែយានយន្តរបស់លោកអ្នកត្រូវបានបាត់ក្នុងពេលតែមួយ

(ឆ) ដោយអំពើព្យាបាទ

(ជ) នៅពេលដែលយានយន្តរបស់លោកអ្នកត្រូវបានដឹកជញ្ជូន (ដោយរួមបញ្ចូលនូវការលើកឡើងនិងការដាក់ចុះយានយន្ត) តាមផ្លូវគោក ផ្លូវដែក ឬ តាមផ្លូវទឹក។

**២. មូលដ្ឋាននៃការដោះស្រាយសំណង**

(ក) ក្រុមហ៊ុនយើងខ្ញុំនឹងមានជម្រើសក្នុងការ :

(i) បង់ថ្លៃដូសជុលយានយន្តរបស់លោកអ្នក ឬ

(ii) សងជាប្រាក់សម្រាប់ថ្លៃបាត់បង់ ឬខូចខាតលើយានយន្តរបស់លោកអ្នក ឬ

(iii) ធ្វើអោយដូចសភាពដើម ឬ ផ្លាស់ប្តូរយានយន្តជូនលោកអ្នក។

(ខ) ចំនួនទឹកប្រាក់អតិបរមាដែលក្រុមហ៊ុនយើងខ្ញុំត្រូវសង គឺជាតម្លៃទីផ្សារនៃយានយន្តរបស់លោកអ្នកនៅពេលបាត់បង់ ឬតម្លៃដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ដោយយកតម្លៃណាមួយដែលតិចជាងគេក្នុងចំណោមតម្លៃទាំងពីរនោះ។

(គ) ប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានធានាដោយទឹកប្រាក់សរុបតិចជាងតម្លៃទីផ្សារគិតនៅពេលមានការបាត់បង់ ឬខូចខាតនោះលោកអ្នកត្រូវបានសន្មត់ថាទទួលរ៉ាប់រងដោយខ្លួនឯងសម្រាប់ភាពខុសគ្នានៃតម្លៃនោះ និងត្រូវទទួលបន្ទុកតាមសមាមាត្រនៃការខាតបង់។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តទេ ប្រសិនបើតម្លៃធានារ៉ាប់រងទាបជាងតម្លៃតាមទីផ្សារនៃយានយន្តនាពេលដែលមានការបាត់បង់ ឬការខូចខាតនោះចំនួន ១០ ភាគរយ ។

(ឃ) ក្នុងករណីមានវិវាទ តម្លៃទីផ្សារនៃយានយន្តរបស់លោកអ្នកនឹងត្រូវកំណត់ដោយការិយាល័យកណ្តាលនៃអ្នកទទួលសិទ្ធលក់យានយន្ត ម៉ាកនោះ(Franchise-holder) ហើយតម្លៃនេះត្រូវស្មើនឹងតម្លៃនៃការទិញយានយន្តជំនួសដែលមានម៉ាក ស៊េរី និងអាយុកាលដូចគ្នាទៅនឹងយានយន្តរបស់លោកអ្នកនៅពេលបាត់បង់។

(ង) ក្នុងករណីដែលគ្មានអ្នកទទួលសិទ្ធិលក់យានយន្ត (Franchise-holder) ដែលមានម៉ាកដូចម៉ាកយានយន្តរបស់លោកអ្នកទេ នោះតម្លៃទីផ្សារនៃយានយន្តរបស់លោកអ្នក នឹងត្រូវកំណត់ដោយបុគ្គលិកដោះស្រាយសំណងរបស់ក្រុមហ៊ុនយើងខ្ញុំ។

(ច) ការកំណត់តម្លៃដោយការិយាល័យកណ្តាលនៃអ្នកទទួលសិទ្ធិលក់យានយន្តម៉ាកនោះ ( Franchise-holder ) ឬដោយបុគ្គលិកដោះស្រាយសំណងរបស់ក្រុមហ៊ុនយើងខ្ញុំនឹងក្លាយជាភស្តុតាងស្ថាពរពាក់ព័ន្ធទៅនឹងការកំណត់តម្លៃទីផ្សារនៃយានយន្តរបស់លោកអ្នកសម្រាប់រាល់នីតិវិធីច្បាប់ទាំងអស់ប្រឆាំងនឹងក្រុមហ៊ុនយើងខ្ញុំ។

(ឆ) ចំនួនទឹកប្រាក់ជាអតិបរមាដែលក្រុមហ៊ុនយើងខ្ញុំ នឹងត្រូវបង់សម្រាប់ការចំណាយជួសជុលយានយន្តរបស់លោកអ្នកត្រូវជាចំណាយចាំបាច់នានាសម្រាប់ស្តារឡើងវិញនូវយានយន្តដែលទទួលការខូចខាតឲ្យត្រឡប់មកដូចសភាពដើម មុនពេលគ្រោះថ្នាក់កើតឡើង (ឬអោយបានប្រហាក់ប្រហែលនឹងសភាពដើមរបស់វាមុនពេលគ្រោះថ្នាក់នោះ ដោយសមរម្យបំផុតតាមដែលអាចធ្វើទៅបាន) តែប៉ុណ្ណោះ។ ប្រសិនបើមានការផ្លាស់ប្តូរគ្រឿងបន្លាស់ថ្មី ( new franchise parts ) ណាមួយ នោះលោកអ្នកនឹងត្រូវចូលរួមចំណែកលើថ្លៃផ្លាស់ប្តូរនេះតាមសមាមាត្រដូចខាងក្រោម:

| **អាយុកាលរបស់យានយន្ត / ឆ្នាំ** | **អត្រាសម្រាប់ការចូលរួមបង់ថ្លៃផ្លាស់ប្តូរគ្រឿងបន្លាស់ថ្មី ( មិនអោយលើសពីភាគរយ (%) ដូចខាងក្រោម )** |
|---|---|
| តិចជាង ៥ ឆ្នាំ | ០ |
| ៥ | ១៥ |
| ៦ | ២០ |
| ៧ | ២៥ |
| ៨ | ៣០ |
| ៩ | ៣៥ |
| ១០ ឆ្នាំឡើងទៅ | ៤០ |

មូលដ្ឋានខាងក្រោមនេះត្រូវបានប្រើដើម្បីកំណត់ពីអាយុកាលរបស់យានយន្ត ៖

| | **អាយុកាលរបស់យានយន្ត ត្រូវកំណត់ដោយផ្អែកទៅលើ ៖** |
|---|---|
| យានយន្តថ្មី | កាលបរិច្ឆេទនៃការចុះបញ្ជី |
| យានយន្តប្រើហើយ / ជជុះនៅក្នុងស្រុក | កាលបរិច្ឆេទនៃការចុះបញ្ជីដើម |
| យានយន្តប្រើហើយ / ជជុះ នាំចូល | ឆ្នាំផលិត |
| យានយន្តជួសជុលឡើងវិញ នាំចូល | ឆ្នាំផលិត |

៣. **ការដឹកជញ្ជូនយានយន្តដែលរងការខូចខាត**

ក្រុមហ៊ុន យើងខ្ញុំនឹងបង់ជូនលោកអ្នកនូវទឹកប្រាក់ជាអតិបរិមាចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក សម្រាប់ថ្លៃដឹកជញ្ជូនយានយន្តរបស់លោកអ្នក ទៅកាន់យានដ្ឋានជួសជុលជិតបំផុត ដែលទទួលស្គាល់ដោយក្រុមហ៊ុន ឬចំពោះថ្លៃអូសទាញយានយន្តរបស់លោកអ្នកត្រឡប់ទៅអាសយដ្ឋានរបស់អ្នកដូចមានចែងនៅក្នុងឧបសម្ព័ន្ធ (Schedule) ឬចំពោះថ្លៃអូសទាញយានយន្តទៅទីសុវត្ថិភាពដើម្បីរក្សាទុកក្នុងលក្ខខណ្ឌដែលយានយន្តរបស់លោកអ្នកត្រូវបានទទួលរងការខូចខាតដោយហេតុការណ៍ទាំងឡាយដូចមានចែងនៅក្នុងផ្នែកនេះ។

៤. **ការបែក និង /ឬស្រាំកញ្ចក់មុខ-ក្រោយ ឬកញ្ចក់ទ្វារ**

ការធ្វើសំណងដែលមានចែងនៅក្នុងផ្នែក **ក** នៃកិច្ចសន្យាធានារ៉ាប់រងនេះ នឹងត្រូវអនុវត្តផងដែរចំពោះរាល់ការទាមទារសំណងលើការផ្លាស់ប្តូរកញ្ចក់មុខ-ក្រោយ ឬកញ្ចក់ទ្វារយានយន្តរបស់លោកអ្នក ប្រសិនបើកញ្ចក់នោះត្រូវបានបែក និង/ឬស្រាំ ( ក្នុងលក្ខខណ្ឌថាពុំមានការខូចខាតផ្សេងទៀតលើយានយន្តរបស់លោកអ្នកឡើយ )។

ការធ្វើសំណងបន្ថែមនេះត្រូវកម្រិតត្រឹមតែមួយករណីប៉ុណ្ណោះនៅរៀងរាល់អំឡុងពេលធានារ៉ាប់រងដោយលោកអ្នកពុំបាត់បង់សិទ្ធបញ្ចុះតម្លៃ (No Claim Discount) ឬត្រូវចូលរួមចំណែកធ្វើសំណងឡើយ។

ក្រោយពីមានការដោះស្រាយសំណងរួចរាល់ហើយផលប្រយោជន៍ដែលកើតចេញមកអំពីការធ្វើសំណងបន្ថែមនេះ នឹងត្រូវបញ្ចប់ លើកលែងតែលោកអ្នកបានបង់បុព្វលាភធានារ៉ាប់រងបន្ថែមដើម្បីទទួលបានអត្ថប្រយោជន៍នេះសារជាថ្មី។

## ករណីលើកលែងចំពោះផ្នែក ក

**ក្រុមហ៊ុនយើងខ្ញុំមិនធ្វើសំណងចំពោះ ៖**

(ក) ការបាត់បង់ផ្នែកហិរញ្ញវត្ថុ (consequential losses) តាមគ្រប់រូបភាព។

(ខ) ការបាត់បង់នូវការប្រើប្រាស់នៃយានយន្តរបស់លោកអ្នក។

(គ) ការធ្លាក់ថ្លៃ ភាពចាស់សំណឹករេចរឹល ច្រេះស៊ី និងការពុក ការខូចផ្នែកគ្រឿងម៉ាស៊ីន ឬផ្នែកអគ្គិសនី ឬផ្នែកអេឡិចត្រូនិច ការមិនដំណើរការគ្រឿងបរិក្ខារ ឬប្រព័ន្ធកុំព្យូទ័ររបស់យានយន្ត ភាពគាំង ឬការបែកបាក់នៃយានយន្តរបស់លោកអ្នក លើកលែងតែការបែកនិង/ស្រាំកញ្ចក់មុខ-ក្រោយកញ្ចក់ទ្វារ ឬដំបូលបិទបើកបាននៃយានយន្តរបស់លោកអ្នក ដោយរួមបញ្ចូលទាំងការបិទកញ្ចក់ការពារកំដៅថ្ងៃប្រសិនបើមាន។

(ឃ) ការខូចខាតដែលបណ្តាលមកពីការផ្ទុក ឬដាក់លើសចំណុះ។

(ង) ការខូចខាតដែលបណ្តាលមកពីការផ្ទុះផ្នែកណាមួយនៃប្រព័ន្ធចំហាយទឹក (boiler) ដែលនៅជាប់ ឬនៅលើយានយន្តរបស់លោកអ្នក។

(ច) ការខូចខាតចំពោះសំបកកង់យានយន្តរបស់លោកអ្នក លើកលែងតែយានយន្តរបស់លោកអ្នក រងការខូចខាតនៅក្នុងពេលជាមួយគ្នាដោយសារគ្រោះថ្នាក់ជាយថាហេតុ។

(ឆ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពី ឬសន្ទតំថាមកពីអំពើឆបោក/បទល្មើសរំលោភលើសេចក្តីទុកចិត្ត ដោយបុគ្គលណាមួយស្របតាមនិយមន័យ នៃបទល្មើសឆបោក/បទល្មើសរំលោភលើសេចក្តីទុកចិត្ត។

(ជ) កម្រិតមិនធ្វើសំណងដែលមានបញ្ញត្តិនៅក្នុងតារាងឧបសម្ព័ន្ធ (Schedule) ។

(ឈ) ការតាំង ឬអសមត្ថភាពនៃគ្រឿងបរិក្ខារ ឬប្រព័ន្ធកុំព្យូទ័រក្នុងការសម្គាល់ ឬបកស្រាយឲ្យបានត្រឹមត្រូវ ឬអនុវត្តកាលបរិច្ឆេទណាមួយថាជាកាលបរិច្ឆេទពិតនិងត្រឹមត្រូវ ឬក្នុងការបន្តដំណើរការដោយត្រឹមត្រូវនៅក្រោយកាលបរិច្ឆេទនោះ។

## ផ្នែក ខ ~ ការទទួលខុសត្រូវចំពោះភាគីតតិយជន

**១.** **ក្រុមហ៊ុននឹងធ្វើសំណងដល់លោកអ្នក ឬអ្នកបើកបរយានយន្តដោយមានការអនុញ្ញាតពីលោកអ្នក ចំពោះចំនួនទឹកប្រាក់ដែលលោកអ្នក ឬ អ្នកបើកបរដោយមានការអនុញ្ញាតរបស់លោកអ្នក ត្រូវបង់ទៅឲ្យភាគីតតិយជន (ដោយរួមបញ្ចូលទាំងសោហ៊ុយ និងចំណាយផ្សេងៗរបស់ដើមបណ្តឹង) សម្រាប់គ្រោះថ្នាក់ដែលបណ្តាលមកពី ឬកើតឡើងពីការប្រើប្រាស់យានយន្តរបស់លោកអ្នក ឬគ្រោះថ្នាក់ដែលពាក់ពន្ធ័នឹងការលើកឡើង ឬដាក់ចុះពីយានយន្តរបស់លោកអ្នកសម្រាប់ :**

(ក) ការស្លាប់ ឬរបួសលើរូបរាងកាយនៃបុគ្គលណាម្នាក់ ក្នុងកម្រិតអតិបរមាចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិកចំពោះបុគ្គលរងគ្រោះម្នាក់ក្នុងគ្រោះថ្នាក់មួយករណី ដោយមិនរាប់បញ្ចូលនូវករណីលើកលែងដូចមានចែងនៅក្នុងផ្នែក **ខ** ។

(ខ) ការខូចខាតលើទ្រព្យសម្បត្តិរបស់តតិយជនដែលបណ្តាលមកពីគ្រោះថ្នាក់បង្កឡើង ដោយការប្រើប្រាស់យានយន្តរបស់លោកអ្នកក្នុងកម្រិតអតិបរមាចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិកក្នុងគ្រោះថ្នាក់មួយករណី។

ភាគីព្រមព្រៀងគ្នាថា អ្នកបើកបរដោយមានការអនុញ្ញាតរបស់លោកអ្នក ត្រូវអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយនៃកិច្ចសន្យាធានារ៉ាប់រងដែលអនុវត្តលើលោកអ្នកផងដែរ។

**២.** **ដែនកំណត់នៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនយើងខ្ញុំ**

ការទទួលខុសត្រូវសរុបរបស់ក្រុមហ៊ុនយើងខ្ញុំនៅក្រោមបញ្ញត្តិនៃផ្នែក**ខ**(១)(ក) **ខ**(១)(ខ) និង**ខ**(៥) មិនត្រូវលើសពីចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក សម្រាប់ការទាមទារសំណងណាមួយ ឬ ការទាមទារសំណងជាច្រើនទាក់ទងគ្នា ដែលកើតចេញអំពីហេតុការណ៍តែមួយ។

**៣.** **ការសណ្តោងយានយន្តដែលខូច**

ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងលើការទទួលខុសត្រូវ ដូចដែលបញ្ជាក់នៅក្នុងផ្នែក **ខ**(១)(ក) និង**ខ**(១)(ខ) ខាងលើប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានប្រើប្រាស់សម្រាប់សណ្តោងយានយន្តដែលខូចខាតណាមួយ។

ដោយហេតុថា :

(ក) ការសណ្តោងយានយន្តទាំងនោះមិនមែនជាថ្នូរនឹងរង្វាន់។

(ខ) ក្រុមហ៊ុនយើងខ្ញុំមិនទទួលខុសត្រូវសម្រាប់ការបាត់បង់ ឬការខូចខាតចំពោះយាន្តយន្តដែលត្រូវបានសណ្តោងទាំងនោះ ឬទ្រព្យសម្បត្តិដែលជាប់នឹង ឬផ្ទុកនៅលើយានយន្ត ដែលត្រូវបានសណ្តោងដោយយានយន្តរបស់លោកអ្នកឡើយ។

**៤.** **សំណងចំពោះអ្នកតំណាងស្របច្បាប់**

បន្ទាប់ពីបុគ្គលណាមួយដែលត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះទទួលមរណភាព ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងជូនដល់អ្នកតំណាងស្របច្បាប់របស់បុគ្គលនោះ ចំពោះរាល់ការទទួលខុសត្រូវដែលធានាដោយបញ្ញត្តិនៃផ្នែកនេះ ក្នុងលក្ខខណ្ឌដែលអ្នកតំណាងស្របច្បាប់នោះគោរពតាមបញ្ញត្តិ និងលក្ខខណ្ឌនានាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។

៥. **ថ្លៃសេវាកម្មផ្នែកច្បាប់**

ក្រុមហ៊ុនយើងខ្ញុំនឹងបង់ថ្លៃសេវាកម្មផ្នែកច្បាប់ជាអតិបរមាចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក ដើម្បីការពារពីការចោទប្រកាន់ណាមួយ ដោយរួមបញ្ចូលនូវការចោទប្រកាន់ពីបទធ្វើអោយបាត់បង់ជីវិត ដោយសារការបើកបរយានយន្ត (ក្រៅពីបទមនុស្សឃាតដោយចេតនា) ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនយើងខ្ញុំ។

## ករណីលើកលែងសម្រាប់ផ្នែក ខ

**ក្រុមហ៊ុនយើងខ្ញុំមិនផ្តល់សំណងចំពោះ :**

(ក) ការស្លាប់ ឬរបួសលើរូបរាងកាយនៃជនណាម្នាក់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដែលបណ្តាលមកពី ឬកើតឡើងពីការលើសដែនកំណត់នៃការប្រើប្រាស់ផ្លូវដឹកជញ្ជូន ឬផ្លូវសាធារណៈផ្សេងៗដែលពាក់ពន្ធ័នឹងការលើកឡើង និងការដាក់ចុះពីយានយន្តរបស់លោកអ្នក។

(ខ) ការស្លាប់ ឬការរបួសលើរូបរាងកាយនៃជនណាមួយម្នាក់ ដែលការស្លាប់ ឬរបួសនោះកើតឡើងដោយសារ និងក្នុងអំឡុងពេលនៃកិច្ចសន្យាការងាររវាងបុគ្គលនោះ និងលោកអ្នក ឬអ្នកបើកបរដោយការអនុញ្ញាតរបស់លោកអ្នក។

(គ) ការស្លាប់ ឬការរបួសលើរូបរាងកាយនៃជនណាម្នាក់ ដែលកំពុងត្រូវបានដឹកជញ្ជូនក្នុង ឬលើ ឬកំពុងចូល ឬឡើង ឬកំពុងចុះពីយានយន្តរបស់លោកអ្នក (លើកលែងតែអ្នកដំណើរទាំងនោះត្រូវបានតម្រូវអោយដឹកជញ្ជូនក្នុង ឬលើយានយន្តរបស់លោកអ្នកដោយហេតុផលនៃ ឬស្របតាមកិច្ចសន្យាការងាររបស់ពួកគេជាមួយលោកអ្នក និង/ឬ អ្នកបើកបរដោយមានការអនុញ្ញាតរបស់លោកអ្នក និង/ឬ និយោជករបស់ពួកគេ)។

(ឃ) ការខូចខាតលើទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់លោកអ្នក ឬនៅក្រោមការកាន់កាប់ ឬការគ្រប់គ្រង ឬក្នុងការថែរក្សារបស់លោកអ្នក និង/ឬអ្នកបើកបរដោយមានការអនុញ្ញាតរបស់លោកអ្នក និង/ឬសមាជិកណាម្នាក់នៃគ្រួសាររបស់លោកអ្នក និង/ឬសមាជិកគ្រួសាររបស់អ្នកបើកបរ ដោយមានការអនុញ្ញាតរបស់លោកអ្នក។

(ង) ការខូចខាតចំពោះស្ពានណាមួយ ផ្លូវស្ពាន ឬស្ពានកាត់ច្រលងភ្នំ ឬផ្លូវណាមួយ ឬស្រទាប់ខាងក្រោមផ្សេងៗទៀតដោយសាររំញ័រ ឬដោយសារទម្ងន់នៃយានយន្ត ឬទម្ងន់ផ្ទុករបស់យានយន្តលោកអ្នក។

(ច) ការខូចខាតចំពោះទ្រព្យសម្បត្តិដែលបណ្តាលមកពី ឬកើតឡើងពីការផ្ទុះផ្នែកណាមួយនៃប្រព័ន្ធចំហាយទឹក (boiler) ដែលនៅជាប់ ឬនៅលើយានយន្តរបស់លោកអ្នក។

(ឆ) ការស្លាប់ ឬរបួសដែលបណ្តាលមកពី ឬកើតឡើងពីការផ្ទុះផ្នែកណាមួយនៃចំហាយទឹក (boiler) ដែលនៅជាប់ ឬនៅលើយានយន្តរបស់លោកអ្នក លើកលែងតែមានការអនុវត្តត្រឹមត្រូវពិសេសតាមច្បាប់តម្រូវ។

(ជ) បណ្តឹងទាមទារសំណងប្រឆាំងបុគ្គលណាម្នាក់ នៅមុខតុលាការក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា។

(ឈ) រាល់ថ្លៃសេវាកម្មផ្នែកច្បាប់ និងសោហ៊ុយទាំងអស់ដែលមិនអាចទាមទារវិញបាន ឬដែលមិនបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## សិទ្ធទទួលបានការបញ្ចុះតម្លៃ ក្នុងករណីមិនមានបណ្តឹងទាមទារសំណង

ប្រសិនបើពុំមានការទាមទារសំណងណាមួយដែលធ្វើឡើង ឬកើតចេញមកអំពីកិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នកទេ ហើយយានយន្តរបស់លោកអ្នកត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនយើងខ្ញុំក្នុងរយៈពេល ១២ ខែ បន្តបន្ទាប់គ្នាសម្រាប់ករណីខាងក្រោមនេះ នោះលោកអ្នកមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនៅពេលចុះកិច្ចសន្យាធានារ៉ាប់រងបន្តជាថ្មីដូចតទៅ :

| **រយៈពេលនៃការធានារ៉ាប់រង** | **ការបញ្ចុះតំលៃ** |
|---|---|
| បន្ទាប់ពីឆ្នាំទី ១ នៃការធានារ៉ាប់រង | ១០% |
| បន្ទាប់ពីឆ្នាំទី ២ នៃការធានារ៉ាប់រង | ១៥% |
| បន្ទាប់ពីឆ្នាំទី ៣ នៃការធានារ៉ាប់រង | ២០% |

ប្រសិនបើក្រុមហ៊ុនយើងខ្ញុំយល់ព្រមលើការផ្ទេរផលប្រយោជន៍នៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ រយៈពេលនៃការធានារ៉ាប់រងដែលផ្តល់ផលប្រយោជន៍នៅក្នុងនាមរបស់លោកអ្នក នឹងមិនត្រូវបានបន្ថែមជាប្រយោជន៍ដល់អ្នកថ្មីឡើយ។

ប្រសិនបើយានយន្តច្រើនគ្រឿងត្រូវបានយកមកចុះកិច្ចសន្យាធានារ៉ាប់រងតែមួយ សិទ្ធិទទួលបានការបញ្ចុះតម្លៃចំពោះការមិនមានបណ្តឹងទាមទារសំណងនេះត្រូវយកមកអនុវត្តទៅយានយន្តនីមួយៗ ប្រៀបដូចជាយានយន្តនីមួយៗមានកិច្ចសន្យាធានារ៉ាប់រងផ្សេងៗគ្នាដែរ។

## ករណីលើកលែងចំពោះបញ្ញត្តិជាក់លាក់មួយចំនួន និងសិទ្ធទាមទារសំណងមកវិញ

១. ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីដែលក្រុមហ៊ុនយើងខ្ញុំបានបង់ទឹកប្រាក់ស្របតាមច្បាប់ ឬ កិច្ចព្រមព្រៀងដែលក្រុមហ៊ុនយើងខ្ញុំមិនត្រូវបង់ធានារ៉ាប់រងទេនោះ លោកអ្នកត្រូវសងទឹកប្រាក់ទាំងនោះមកក្រុមហ៊ុនយើងខ្ញុំវិញ។

២. ក្នុងករណីដែលក្រុមហ៊ុនយើងខ្ញុំបានធ្វើសំណង ចំពោះការទាមទារលើការខូចខាតយានយន្តរបស់លោកអ្នក (Own Damage Claim) ព្រមទាំងសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិរបស់តតិយជន លោកអ្នកត្រូវលះបង់ និង/ឬ ប្រគល់ទឹកប្រាក់ដែលក្រុមហ៊ុនយើងខ្ញុំបានបង់នោះមកវិញ បើមិនដូច្នោះទេក្រុមហ៊ុនមានសិទ្ធិប្តឹងទាមទារចំនួនទឹកប្រាក់នេះមកវិញ ព្រមទាំងសោហ៊ុយ ឬការចំណាយផ្សេងៗដែលកើតមានឡើង។

## ករណីលើកលែងទូទៅទាំងនេះត្រូវអនុវត្តលើកិច្ចសន្យាធានារ៉ាប់រងទាំងមូល

**ក្រុមហ៊ុនយើងខ្ញុំមិនធ្វើសំណងចំពោះការទទួលខុសត្រូវណាមួយ ក្នុងកាលៈទេសៈទាំងឡាយដូចខាងក្រោមនេះឡើយ :**

១. ប្រសិនបើលោកអ្នក ឬអ្នកបើកបរដែលលោកអ្នកអនុញ្ញាត ពុំមានប័ណ្ណបើកបរយានយន្ត លើកលែងតែលោកអ្នក ឬអ្នកដែលលោកអ្នកបានអនុញ្ញាតមានប័ណ្ណបើកបរយានយន្ត ហើយមិនត្រូវបានគេដកហូតសិទ្ធិកាន់កាប់ឬទទួលបានប័ណ្ណបើកបរយានយន្តក្នុងការបើកបរស្របតាមបញ្ញត្តិច្បាប់លក្ខន្តិកៈ និងបទបញ្ជាចាំបាច់ទាំងឡាយ។

២. ប្រសិនបើលោកអ្នក ឬអ្នកបើកបរដោយមានការអនុញ្ញាតរបស់លោកអ្នក បើកយានយន្តក្នុងពេលស្រវឹង ឬ ពេលកំពុងទទួលរងឥទ្ធិពលថ្នាំញៀនដល់កម្រិត ដែលមិនអាចគ្រប់គ្រងយានយន្តរបស់លោកអ្នកបាន។

៣. ក) ការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវណាមួយដែលបណ្តាលមកពីយានយន្តរបស់លោកអ្នកត្រូវបានប្រើប្រាស់ក្នុងគោលបំណងមិនស្របច្បាប់ ឬ ត្រូវបានប្រើប្រាស់ពុំសមស្របតាមការកំណត់នៃការប្រើប្រាស់ ( Limitations as to use ) ដោយលោកអ្នក ឬបុគ្គលដទៃទៀតដោយមានការយល់ព្រមពីលោកអ្នក។

ខ) ការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដែលបណ្តាលមកពី ឬកើតមានឡើងក្នុងពេលដែលយានយន្តរបស់លោកអ្នកត្រូវបានបើកបរដោយបុគ្គលណាមួយក្រៅពីអ្នកបើកបរដោយមានការអនុញ្ញាតពីលោកអ្នក ឬក្រៅពីបុគ្គលដែលបើកបរតាមបញ្ជា ឬដោយមានការអនុញ្ញាតពីលោកអ្នក។

៤. ប្រសិនបើការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវណាមួយបណ្តាលមកពីការឈ្លានពាន សង្គ្រាម (ទោះជាសង្គ្រាមនោះត្រូវបានប្រកាស ឬ មិនត្រូវបានប្រកាសក៏ដោយ) ប្រតិបត្តិការសង្គ្រាម អំពើរបស់សត្រូវបរទេស ចំបាំងសង្គ្រាមស៊ីវិល អំពើភេរវកម្ម កូដកម្ម កុប្បកម្ម ការរំជើបរំជួលស៊ីវិល ការបះបោរ ចលនាឧទ្ទាម បដិវត្តន៍ ការប្រើកងទ័ព ឬការដណ្តើមអំណាច ឬដោយហេតុបច្ច័យផ្ទាល់ ឬដោយប្រយោលនៃហេតុការណ៍ទាំងនេះ។

៥. ប្រសិនបើការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពី ឬចូលរួមអោយកើតឡើងដោយ ឬកើតឡើងពីទឹកជំនន់ ខ្យល់ព្យុះសង្ឃរា ខ្យល់ព្យុះ ព្យុះភ្លៀង បន្ទុះភ្នំភ្លើង រញ្ជួយដី ការស្រុតចុះនៃផ្ទាំងដី បំណាក់ស្រុតដី ការធ្លាក់ចុះ ឬលិចនៃផ្ទាំងដី (Subsidence or sinking of the soil/earth) ឬគ្រោះធម្មជាតិផ្សេងទៀត។

៦. ប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានប្រើប្រាស់សម្រាប់ ឬកំពុងត្រូវបានធ្វើការសាកល្បងនៅក្នុងការរៀបចំសម្រាប់កីឡា ឬការប្រកួតប្រជែងយានយន្តណាមួយ (លើកលែងល្បែងរករកវត្ថុមានតម្លៃ) ។ អំពើទាំងនេះមានដូចជា ( តែមិនកំណត់ត្រឹមតែ) ការសាកល្បងពីភាពដែលអាចទុកចិត្តបាន ការសាកល្បងបើកឡើងភ្នំ និងការប្រណាំងរថយន្តនានា។

៧. នៅក្នុងករណីមានគ្រោះថ្នាក់ ឬការខូចខាតណាមួយ ប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានទុកចោល ដោយគ្មានវិធានការការពារអោយបានត្រឹមត្រូវ ដើម្បីការពារការបាត់បង់ ឬការខូចខាតបន្ថែមទៀត និងប្រសិនបើយានយន្តរបស់លោកអ្នកត្រូវបានបើកបរក្នុងស្ថានភាពដែលពុំអាចបើកបរបានមុនពេលមានការជួសជុលចាំបាច់នានានោះទេ រាល់ការខូចខាតបន្ថែមទៀតលើយានយន្តរបស់លោកអ្នកនឹងមិនត្រូវរាប់បញ្ចូលនៅក្នុងការធានារ៉ាប់រងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។

៨. ចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដោយថាហេតុណាមួយដែលបណ្តាលមកពី ឬកើតមានឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៩. ការទទួលខុសត្រូវណាមួយដែលភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងណាមួយ ដែលក្រុមហ៊ុនយើងខ្ញុំនឹងពុំត្រូវទទួលខុសត្រូវឡើយ ប្រសិនបើគ្មានកិច្ចព្រមព្រៀងទាំងនោះ។

១០ (ក) ការបាត់បង់ ឬការខូចខាតដោយថាហេតុណាមួយចំពោះទ្រព្យសម្បត្តិណាមួយក៏ដោយ ឬការបាត់បង់ ឬការចំណាយណាមួយក៏ដោយ ឬដែលកើតចេញអំពីការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិនោះ ឬ ការខាតបង់ផ្នែកហិរញ្ញវត្ថុណាមួយដែលអាចកើតឡើង។

(ខ) រាល់ការទទួលខុសត្រូវគ្រប់ប្រភេទទាំងអស់ដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពី ឬចូលរួមឲ្យកើតឡើង ឬកើតឡើងពីសារធាតុវិទ្យុសកម្ម ឬការសាយភាយនៃជាតិវិទ្យុសកម្មមកអំពីឥន្ធនៈនុយក្លេអ៊ែរ ឬពីកាកសំណល់នុយក្លេអ៊ែរពីចំហេះនៃឥន្ធនៈនុយក្លេអ៊ែរ។ ក្នុងន័យនៃបញ្ញត្តិនេះ ចំហេះត្រូវកើតឡើងពីដំណើរការទ្រទ្រង់បន្ទុះដោយខ្លួនឯងនៃសារធាតុនុយក្លេអ៊ែរ។

១១. ការបាត់បង់ ឬការខូចខាតដោយថាហេតុណាមួយដែលបណ្តាលមកពី ឬចូលរួមឲ្យកើតឡើង ឬកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីអាវុធ និងសម្ភារនុយក្លេអ៊ែរ។

**ប្រសិនបើច្បាប់មួយ ឬច្រើនត្រូវបានវាយឈ្មោះនៅក្នុងផ្នែក "ករណីលើកលែងចំពោះបញ្ញត្តិជាក់លាក់មួយចំនួន និងសិទ្ធទាមទារសំណងមកវិញ" ឬនៅក្នុងឧបសម្ព័ន្ធកិច្ចសន្យាធានារ៉ាប់រងនេះ "ច្បាប់" នៃកិច្ចសន្យាធានារ៉ាប់រងនេះ រាល់សេចក្តីយោងទាំងអស់ចំពោះផ្នែកដោយឡែកណាមួយនៃច្បាប់ទាំងនោះ ត្រូវចាត់ទុកថាត្រូវបានលុបចោល ដើម្បីអនុញ្ញាតអោយច្បាប់ទាំងនោះអាចអនុវត្តបានទាំងស្រុង។**

## លក្ខខណ្ឌខាងក្រោមនេះត្រូវអនុវត្តលើកិច្ចសន្យាធានារ៉ាប់រងទាំងមូល

១. **កាតព្វកិច្ចនៃការផ្តល់ព័ត៌មាន**

ប្រសិនបើលោកអ្នកខកខានក្នុងការផ្តល់ឲ្យបានពេញលេញ និងដោយស្មោះត្រង់មកអោយក្រុមហ៊ុនយើងខ្ញុំនូវហេតុការណ៍ទាំងអស់ដែលលោកអ្នកដឹង ឬគួរតែដឹង ឬប្រសិនបើលោកអ្នកបានផ្តល់ព័ត៌មានមិនពិតអំពីហេតុការណ៍ណាមួយមកក្រុមហ៊ុនយើងខ្ញុំ នៅមុនការចុះកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុនយើងខ្ញុំអាចនឹងបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះ។

លោកអ្នកត្រូវតែគោរព និងប្រតិបត្តិតាមបញ្ញត្តិ លក្ខខណ្ឌ បដិលេខ ខសន្យា ឬការធានាទាំងឡាយនៃកិច្ចសន្យាធានារ៉ាប់រងនេះ។

## ២. គ្រោះថ្នាក់ និងនីតិវិធីទាមទារសំណង

(ក) លោកអ្នកត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនយើងខ្ញុំអំពីព័ត៌មានលម្អិតអោយបានឆាប់បំផុតតាមដែលអាចធ្វើបាន បន្ទាប់ពីមានហេតុការណ៍ណាមួយដែលអាចក្លាយជាកម្មវត្ថុនៃការទាមទារសំណងស្របតាមបញ្ញត្តិនៃកិច្ចសន្យាធានារ៉ាប់រងនេះ។

(ខ) រាល់គ្រោះថ្នាក់ទាំងអស់ត្រូវរាយការណ៍ទៅនគរបាលតាមបញ្ញត្តិច្បាប់ជាធរមាន។

(គ) គ្រប់ឯកសារទំនាក់ទំនង លិខិតបញ្ជារបស់តុលាការ ដីកាកោះ និងបែបបទនីតិវិធីនានាអំពីភាគីពាក់ព័ន្ធដទៃទៀត ត្រូវផ្ញើមកកាន់ក្រុមហ៊ុនយើងខ្ញុំជាបន្ទាន់។ លោកអ្នកត្រូវផ្តល់ព័ត៌មានជាបន្ទាន់ មកកាន់ក្រុមហ៊ុនយើងខ្ញុំ ប្រសិនបើលោកអ្នកបានដឹងពីការស៊ើបសួរសម្រាប់ការចោទប្រកាន់ ដែលអាចកើតមានឡើង ឬការអង្កេតទាក់ទងនឹងគ្រោះថ្នាក់ដល់អាយុជីវិត (fatal inquiry) ណាមួយ។ នៅក្នុងករណីនៃអំពើចោរកម្ម ឬអំពើដទៃទៀតដែលអាចនាំអោយមានការទាមទារសំណងនៅក្រោមបញ្ញត្តិនៃកិច្ចសន្យាធានារ៉ាប់រងនេះ លោកអ្នកត្រូវរាយការណ៍ជាបន្ទាន់ទៅនគរបាល និងសហការជាមួយក្រុមហ៊ុនយើងខ្ញុំដើម្បីធ្វើការចោទប្រកាន់លើជនល្មើស។

(ឃ) គ្មានការចរចារ ការព្រមទទួល ឬការបដិសេធនៃការទាមទារសំណងណាមួយអាចយកជាការបាន ដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនយើងខ្ញុំឡើយ។

(ង) ក្រុមហ៊ុនយើងខ្ញុំមានឆន្ទានុសិទ្ធិពេញទីក្នុងការទាមទារ ការពារ និង/ឬដោះស្រាយការទាមទារណាមួយ។

(ច) គ្មានការជួសជុលណាមួយលើយានយន្តរបស់លោកអ្នក ត្រូវបានអនុញ្ញាតដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនយើងខ្ញុំឡើយ។

(ឆ) ក្នុងករណីដែលយានយន្តរបស់លោកអ្នកមានការពាក់ព័ន្ធនឹងគ្រោះថ្នាក់ ហើយដែលនាំឲ្យមានការទាមទារសំណងយានយន្តរបស់លោកអ្នកត្រូវបញ្ជូនទៅកាន់យានដ្ឋានជួសជុល ដែលទទួលស្គាល់ដោយក្រុមហ៊ុនដែលនៅជិតបំផុតដើម្បីធ្វើការជួសជុល។ ការខកខានមិនបានបញ្ជូនយានយន្តទៅយានដ្ឋានដែលទទួលស្គាល់ដោយក្រុមហ៊ុនយើងខ្ញុំ គឺជាការរំលោភលើលក្ខខណ្ឌនេះ ហើយក្រុមហ៊ុនយើងខ្ញុំមានសិទ្ធិបដិសេធមិនទទួលខុសត្រូវនៅក្រោមបញ្ញត្តិផ្នែក ៣ នៃកិច្ចសន្យាធានារ៉ាប់រងនេះ។

(ជ) នៅក្នុងហេតុការណ៍ណាមួយដែលនាំឲ្យកើតមានការទាមទារសំណងមួយ ឬច្រើនទាក់ទងគ្នា ស្របតាមបញ្ញត្តិនៃផ្នែក ២ (១) (ខ) នៃកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុនយើងខ្ញុំអាចសងពេញថ្លៃនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនយើងខ្ញុំ ស្របតាមបញ្ញត្តិនៃផ្នែក ២ (១) (ខ) ហើយនឹងលះបង់នូវការការពារ ការដោះស្រាយ ឬការធ្វើបណ្តឹងណាមួយ ហើយក្រុមហ៊ុនយើងខ្ញុំមិនទទួលខុសត្រូវចំពោះការខូចខាតដែលត្រូវបានលើកឡើងថា បានកើតឡើងចំពោះលោកអ្នក ដែលជាលទ្ធផលនៃអំពើ ឬការខកខានណាមួយរបស់ក្រុមហ៊ុនយើងខ្ញុំ ដែលទាក់ទងនឹងការការពារ ការដោះស្រាយ ឬការប្តឹង ឬការលះបង់អំពើទាំងនេះ ឬក្រុមហ៊ុនក៏មិនត្រូវទទួលរ៉ាប់រងនូវរាល់សោហ៊ុយ ឬការចំណាយណាមួយក៏ដោយរបស់លោកអ្នក ឬរបស់អ្នកទាមទារ ឬរបស់បុគ្គលណាមួយ ក្រោយពេលដែលក្រុមហ៊ុនបានលះបង់សិទ្ធិមិនធ្វើការការពារ ការទាមទារ ការស្រាយឬការធ្វើបណ្តឹងណាមួយនោះ។

## ៣. ការសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រង

(ក) លោកអ្នកអាចសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះបានគ្រប់ពេលវេលា ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រុមហ៊ុនយើងខ្ញុំ។

(ខ) ក្រុមហ៊ុនយើងខ្ញុំអាចបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះបានដែរដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១០ថ្ងៃជាមុនទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយរបស់លោកអ្នក។

(គ) ក្នុងរយៈពេល ៧ ថ្ងៃចាប់តាំងពីថ្ងៃសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះស្របតាមកថាខណ្ឌ (ក) និង (ខ) ខាងលើ លោកអ្នកត្រូវប្រគល់អោយក្រុមហ៊ុនយើងខ្ញុំវិញនូវវិញ្ញាបនប័ត្រធានារ៉ាប់រង ឬ ប្រសិនបើវិញ្ញាបនប័ត្រនេះត្រូវបានបាត់បង់ ឬ កម្ទេចចោល ឬប្រសិនវាពុំត្រូវបានទទួលដោយលោកអ្នកទេលោកអ្នកត្រូវតែផ្តល់ឲ្យក្រុមហ៊ុនយើងខ្ញុំនូវសេចក្តីប្រកាសជាផ្លូវការសម្រាប់បញ្ជាក់ហេតុការណ៍ទាំងនេះ។

(ឃ) ក្នុងករណីដែលលោកអ្នកសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះ (និងក្នុងលក្ខខណ្ឌថាពុំមានការទាមទារសំណងណាមួយកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ) លោកអ្នកត្រូវមានសិទ្ធិទទួលបានការបង្វិលសងវិញចំនួនកៅសិបភាគរយ ៩០% នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់គិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ។

(ង) ក្នុងករណីដែលក្រុមហ៊ុនយើងខ្ញុំសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រងនេះ លោកអ្នកមានសិទ្ធិទទួលបានការបង្វិលសងវិញនូវអត្រាបុព្វលាភធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ។

(ច) រាល់ការសុំបញ្ឈប់កិច្ចសន្យាធានារ៉ាប់រង លោកអ្នកនឹងពុំត្រូវបានទទួលការបង្វិលសងបុព្វលាភវិញឡើយ ប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បរមា។

## ៤. ការធានារ៉ាប់រងដទៃទៀត

លោកអ្នកត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនយើងខ្ញុំ ប្រសិនបើលោកអ្នកមានធានារ៉ាប់រងពីក្រុមហ៊ុនដទៃទៀតលើយានយន្តរបស់លោកអ្នក។ ប្រសិនបើនៅពេលទាមទារសំណងណាមួយ ស្របតាមបញ្ញត្តិនៃកិច្ចសន្យាធានារ៉ាប់រងនេះមានការធានារ៉ាប់រងពីក្រុមហ៊ុនដទៃទៀតចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដូចគ្នា ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើសំណងត្រឹមតែសមាមាត្រដែលអាចវាយតម្លៃបាននៃការបាត់បង់ ការខូចខាត សំណងការខាតបង់ ឬ ចំណាយទាំងឡាយដែលមានប៉ុណ្ណោះ។ ក៏ប៉ុន្តែលក្ខខណ្ឌនេះមិនត្រូវដាក់កាតព្វកិច្ចអោយក្រុមហ៊ុនយើងខ្ញុំនូវការទទួលខុសត្រូវណាមួយដែលក្រុមហ៊ុនយើងខ្ញុំមិនបានព្រមព្រៀងធានារ៉ាប់រងឡើយ។

## ៥. សិទ្ធិជំនួស

ក្រុមហ៊ុនយើងខ្ញុំ ដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន មានសិទ្ធិធ្វើការការពារ ឬដោះស្រាយ ការទាមទារសំណង ឬដាក់ពាក្យចោទប្រកាន់ទាមទារសំណង ឬការជួសជុលការខូចខាតនានាក្នុងនាមរបស់លោកអ្នក សម្រាប់ជាប្រយោជន៍របស់ក្រុមហ៊ុន។ ក្រុមហ៊ុនយើងខ្ញុំមានឆន្ទានុសិទ្ធិដាច់ខាត ក្នុងដំណើរការនីតិវិធីទាំងឡាយនៅក្នុងការដោះស្រាយការទាមទារណាមួយ ហើយលោកអ្នកត្រូវតែផ្តល់ឲ្យក្រុមហ៊ុនយើងខ្ញុំនូវព័ត៌មាន និងជំនួយតាមតម្រូវការរបស់ក្រុមហ៊ុនយើងខ្ញុំ។

## ៦. ខ ចែងស្តីអំពីមជ្ឈត្តការ

នៅពេលមានវិវាទកើតមានឡើងពីកិច្ចសន្យាធានារ៉ាប់រងនេះ នោះវិវាទត្រូវដាក់ឲ្យដោះស្រាយ ដោយមជ្ឈត្តករមួយរូបដែលនឹងត្រូវជ្រើសរើសជាលាយលក្ខណ៍អក្សរដោយលោកអ្នក និងក្រុមហ៊ុនយើងខ្ញុំ។ ក្នុងករណីដែលលោកអ្នកនិងក្រុមហ៊ុនយើងខ្ញុំពុំអាចព្រមព្រៀងគ្នាក្នុងការជ្រើសរើសមជ្ឈត្តករក្នុងរយៈពេល ១ ខែ គិតចាប់ពីថ្ងៃដែលមានការតម្រូវជាលាយលក្ខណ៍អក្សរឲ្យធ្វើដូចនោះទេ នោះលោកអ្នក និងក្រុមហ៊ុនត្រូវជ្រើសរើសមជ្ឈត្តករម្នាក់មួយដែលមជ្ឈត្តករទាំង២រូបនេះត្រូវធ្វើការដោះស្រាយវិវាទនោះរួមគ្នានឹងមជ្ឈត្តករម្នាក់ទៀតដែលជ្រើសរើសដោយមជ្ឈត្តករទាំងពីររូបនេះ។ ក៏ប៉ុន្តែភាគីបានព្រមព្រៀងគ្នាថាការបដិសេធមិនទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះការទាមទារណាមួយនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវដាក់ឲ្យដោះស្រាយដោយធ្វើមជ្ឈត្តការនៅក្នុងរយៈពេល ១២ខែ នៃខែប្រតិទិនចាប់ពីពេលថ្ងៃបដិសេធនោះ។

## ៧. ខ ចែងស្តីអំពីការធានាចំពោះបុព្វលាភធានារ៉ាប់រង

លក្ខខណ្ឌសំខាន់បំផុត និងដាច់ខាតនៃកិច្ចសន្យាធានារ៉ាប់រងនេះ គឺប្រាក់បុព្វលាភដែលដល់ពេលកំណត់ត្រូវបង់ និងទទួលដោយក្រុមហ៊ុនយើងខ្ញុំនៅក្នុងរយៈពេលសាមសិបថ្ងៃ (៣០) គិតចាប់ពីថ្ងៃចាប់ផ្តើមនៃកិច្ចសន្យាធានារ៉ាប់រង/បង្កាន់ដៃ/បន្តវិញ្ញាបនប័ត្រថ្មី។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេកិច្ចសន្យានេះ ត្រូវចាត់ទុកជាអសារបង់ដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនយើងខ្ញុំមានសិទ្ធិទទួលបានសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេលដែលក្រុមហ៊ុនស្ថិតនៅក្នុងហានិភ័យ។

នៅពេលដែលបុព្វលាភដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារដែលទទួលការអនុញ្ញាតរបស់ក្រុមហ៊ុនយើងខ្ញុំ ការបង់បុព្វលាភនេះត្រូវបានចាត់ទុកថាត្រូវបានទទួលដោយក្រុមហ៊ុនយើងខ្ញុំសម្រាប់គោលដៅនៃការធានានេះ ហើយក្រុមហ៊ុនយើងខ្ញុំមានបន្ទុកក្នុងការបង្ហាញភស្តុតាងផ្ទុយថា បុព្វលាភនេះត្រូវបានទទួលដោយបុគ្គលមួយរូប រាប់បញ្ចូលទាំងភ្នាក់ងារធានារ៉ាប់រងផងដែរ ដែលពុំត្រូវបានអនុញ្ញាតឲ្យទទួលបុព្វលាភនេះ។ រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

៨. **បញ្ញត្តិផ្សេងៗ**

កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវអនុវត្តតែក្នុងករណីដែល :

(ក) បុគ្គលណាម្នាក់ដែលទាមទារការការពារនោះ បានអនុវត្តស្របតាមបញ្ញត្តិ លក្ខខណ្ឌ បដិលេខ ខសន្យា ឬការធានាទាំងអស់នៃកិច្ចសន្យាធានារ៉ាប់រងនេះ។

(ខ) លោកអ្នកបានប្រកាន់នូវរាល់វិធានការសមស្របទាំងឡាយ ដើម្បីថែរក្សាយានយន្តរបស់លោកអ្នកឲ្យស្ថិតក្នុងស្ថានភាពដែលអាចបើកបរបាន។

(គ) លោកអ្នកបានចាត់វិធានការសមស្របទាំងឡាយ ដើម្បីរក្សាការពារយានយន្តមិនអោយបាត់បង់ ឬ ខូចខាត។

(ឃ) លោកអ្នកត្រូវអនុញ្ញាតឲ្យយើងខ្ញុំពិនិត្យយានយន្តបាននៅគ្រប់ពេលវេលាដែលសមរម្យ។

៩. **ខ ចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង (LMA 3100)**

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះឡើយ ដែលការផ្តល់ប្រាក់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើឲ្យក្រុមហ៊ុនប្រឈមមុខ នឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយ័តកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

## និយមន័យនៃពាក្យដែលត្រូវគូសចំណាំនៅក្នុងកិច្ចសន្យាធានារ៉ាប់រង

១. **យើង** សំដៅលើក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំ ។

២. **អ្នក/របស់អ្នក/ខ្លួនអ្នក/លោកអ្នក** សំដៅលើអ្នកដែលមានកិច្ចសន្យាធានារ៉ាប់រង និង/ឬ បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៣. **យានយន្តរបស់លោកអ្នក** សំដៅលើយានយន្ត គ្រឿងបន្ទាប់បន្សំបំពាក់ពីរោងចក្រផលិតតាមស្តង់ដារ និងគ្រឿងបន្ទាប់បន្សំបន្ថែមផ្សេងទៀត ដូចដែលមានកំនត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រងនេះ ។

៤. **គ្រឿងបន្ទាប់បន្សំ** សំដៅលើឧបករណ៍ស្តង់ដារនៃយានយន្ត ដែលរួមបញ្ចូលទាំងម៉ាស៊ីនត្រជាក់ កង់បម្រុង និងអាចជា វិទ្យុ/ម៉ាញ៉េ/ម៉ាស៊ីនចាក់ឌីស និងឧបករណ៍ស្រដៀងគ្នាផ្សេងៗទៀត ដូចមានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រងនេះ ។

៥. **យានដ្ឋានជួសជុល** សំដៅលើរោងជាងជួសជុលយានយន្ត ដែលត្រូវបានទទួលស្គាល់ដោយក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំ ។

៦. **គ្រួសាររបស់អ្នក** សំដៅលើសមាជិកនៃគ្រួសារផ្ទាល់របស់លោកអ្នក (ពោលគឺសហព័ទ្ធ កូនដែលរាប់បញ្ចូលទាំងកូនចិញ្ចឹមស្របច្បាប់ ឪពុកម្តាយ បងប្អូនបង្កើត)។

៧.	**អំពើឆបោក**មានន័យដូចខាងក្រោម ៖

ជនណាដែលតាមរយៈការបោកបន្លំជនណាម្នាក់ទៀត បើទោះជាអំពើបន្លំនោះជាការបញ្ឆោះបញ្ឆូលតែម្យ៉ាង ឬជាអំពើចម្បងមួយ ឬមិនមែនក៏ដោយ ៖

(ក)	បញ្ឆោះបញ្ឆូលដោយបន្លំ ឬដោយមិនស្មោះត្រង់ជនណាម្នាក់ទៀតឲ្យចាញ់បោកព្រមប្រគល់ទ្រព្យសម្បត្តិណាមួយទៅឲ្យជនណាម្នាក់ ឬព្រមព្រៀងអោយជនម្នាក់នោះរក្សាទ្រព្យសម្បត្តិនោះទុក ឬ

(ខ)	បញ្ឆោះបញ្ឆូលដោយចេតនាជនណាម្នាក់ឲ្យចាញ់បោកព្រមធ្វើអំពើ ឬមិនធ្វើអំពើណាមួយដែលជននោះ នឹងមិនធ្វើ ឬមិនខកខានធ្វើឡើយប្រសិនបើខ្លួនពុំត្រូវបានគេបោកបន្លំទេនោះហើយដែលអំពើ ឬការមិនធ្វើអំពើនោះបង្កឲ្យមាន ឬអាចបង្កអោយមានការខូចខាត ឬបង្កគ្រោះថ្នាក់ដល់បុគ្គលដទៃទៀតទាំងផ្លូវកាយផ្លូវចិត្ត កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិ ឲ្យឈ្មោះថា "**អំពើឆបោក**"។

៨.	**បទល្មើសរំលោភលើសេចក្តីទុកចិត្ត** មានន័យដូចខាងក្រោម ៖

ជនណាដែលត្រូវបានគេផ្ញើទុកនូវទ្រព្យណាមួយទោះតាមវិធីណាក៏ដោយ ឬដែលមានសិទ្ធិគ្រប់គ្រងលើទ្រព្យមួយទោះបីតែម្នាក់ឯង ឬរួមគ្នាជាមួយបុគ្គលផ្សេងក៏ដោយបន្លំយកដោយទុច្ចរិតនូវទ្រព្យនោះ ឬបង្វែរទ្រព្យនោះមកជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ ឬចាត់ចែងទ្រព្យនោះដោយទុច្ចរិត ដោយរំលោភលើវិធានច្បាប់ដែលបញ្ញត្តិពីរបៀបដោះបន្ទុកលើការផ្ញើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ ឬដោយតុល្យភាពដែលអនុញ្ញាតឲ្យខ្លួនរួចបន្ទុកពីការផ្ញើទុកនោះ ឬដោយចេតនាបង្កឲ្យបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើត្រូវចាត់ទុកថាបានប្រព្រឹត្ត "**បទល្មើសរំលោភលើសេចក្តីទុកចិត្ត**"។

៩.	**អំពើភេរវកម្ម**

មានន័យថាជាអំពើមួយដែលរួមមានតែមិនកំណត់ចំពោះការប្រើកំលាំងហិង្សាឬគំរាមកំហែងនិងប្រើកំលាំងហិង្សាដោយបុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយទោះជាធ្វើឡើងម្នាក់ឯងក្តី ឬធ្វើឡើងក្នុងនាម ឬពាក់ព័ន្ធនឹងអង្គការឬរដ្ឋាភិបាលណាមួយដែលត្រូវបានធ្វើឡើងក្នុងគោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលដៅប្រហាក់ប្រហែល ដែលរាប់បញ្ចូលទាំងចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលមួយ និង/ឬធ្វើអោយសាធារណៈជន ឬក្រុមមនុស្សណាមួយមានការភ័យខ្លាច។

## ការធានា/បដិលេខ/ខសន្យាដែលត្រូវអនុវត្ត ដូចដែលមានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រង

### បដិលេខ ១. កម្រិតមិនធ្វើសំណង

លោកអ្នកត្រូវទទួលខុសត្រូវក្នុងការបង់ចំនួនទឹកប្រាក់ដំបូង ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រង សម្រាប់រាល់ការទាមទារសំណង ( ដែលរួមមានការចំណាយ និងសោហ៊ុយនានា និងការចំណាយរបស់ក្រុមហ៊ុននៅក្នុងការធ្វើការការពារ និងដោះស្រាយការទាមទារនានា ) ស្របតាមផ្នែក **អ** នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយបន្ថែមលើកម្រិតមិនធ្វើសំណងដទៃទៀតដែលអាចយកមកអនុវត្ត ។

ប្រសិនបើការចំណាយរបស់ក្រុមហ៊ុនយើងខ្ញុំមានរួមបញ្ចូលនូវទឹកប្រាក់ដែលលោកអ្នកត្រូវបង់ លោកអ្នកត្រូវសងចំនួនទឹកប្រាក់នោះដល់ក្រុមហ៊ុនយើងខ្ញុំវិញ ។

រាល់លក្ខខណ្ឌ និងខចែងទាំងអស់នេះត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

កំណត់ចំណាំ ៖ ការចូលរួមចំណែកធ្វើសំណងរបស់លោកអ្នក ដែលមានបញ្ញត្តិនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវអនុវត្តបន្ថែមលើកម្រិតមិនធ្វើសំណងដទៃទៀតដែលអាចត្រូវអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងនេះ ។

**បង្ហិលេខ ៣ (P). ចំពោះតតិយជនប៉ុណ្ណោះ**

សំណាងស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះត្រូវអនុវត្តសម្រាប់តែភាគីតតិយជនប៉ុណ្ណោះបានន័យថា
ផ្នែក **ខ** (ការទទួលខុសត្រូវចំពោះភាគីតតិយជន)
ផ្នែក **ឥ** (ការបាត់បង់ ឬការខូចខាតចំពោះយានយន្តរបស់អ្នក) ត្រូវបានលើកលែង

រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

**បង្ហិលេខ ១៩. ហានិភ័យនៃការដឹកជញ្ជូនអ្នកដំណើរ**

ក្រុមហ៊ុនយើងខ្ញុំព្រមព្រៀងថា ករណីលើកលែងចំណុច (គ) នៃផ្នែក ខ ដែលមានក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានចាត់ទុកជាអសារបង់ ។

* ដោយហេតុថា ក្នុងករណីដែលមានគ្រោះថ្នាក់កើតឡើង យានយន្តរបស់លោកអ្នកបានផ្ទុកអ្នកដំណើរលើសចំនួនកំណត់ដោយផ្អែកតាមច្បាប់ណាមួយ (រួមមានអ្នកជំនួយ/អ្នកណែនាំប្រសិនបើមាន និងអ្នកបើកបរ) ។ លោកអ្នកត្រូវបង់សងដល់ក្រុមហ៊ុនយើងខ្ញុំវិញ តាមអត្រាសមាមាត្រនៃចំនួនទឹកប្រាក់សរុបដែលបានបង់ជូនដោយក្រុមហ៊ុនយើងខ្ញុំ ។

ដោយហេតុថា ចំនួនសរុបនៃអ្នកដំណើរដែលពាក់ពន្ធ័សម្រាប់គោលបំណងនៃលក្ខខណ្ឌខាងលើនេះ អាចនឹងត្រូវបានកែប្រែដោយអនុលោមតាមច្បាប់ណាមួយដែលអនុវត្តចំពោះការផ្ទុកអ្នកដំណើរដែលជាកុមារនៅក្នុងយានយន្ត។

រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។